Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយភ្លាមៗ

# នៅក្នុងសុន្ទរកថាប្រចាំឆ្នាំ នាយកប្រតិបត្តិលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គលើកឡើងពីវឌ្ឍនភាព ចំពេលមាននិន្នាការដ៏គួរឱ្យព្រួយបារម្ភ

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣** – ថ្លែងនៅក្នុងសុន្ទរកថាលើកទីពីររបស់ខ្លួននាថ្ងៃនេះ ស្តីពីស្ថានភាពទន្លេមេគង្គ នាយកប្រតិបត្តិនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ បានរៀបរាប់ពីការប្រឈមរបស់ទន្លេមេគង្គដែលមាននិន្នាការ «ដ៏គួរឱ្យព្រួយបារម្ភ» ដោយផ្តោតលើទិដ្ឋភាពសំខាន់ៗចំនួនប្រាំ រួមមាន៖ របបរំហូរទឹក កំណកកករ ការជ្រៀតចូលរបស់ទឹកប្រៃ ការបំពុលដោយប្លាស្ទិក និងទឹកជំនន់ និងគ្រោះរាំងស្ងួតដោយសារការប្រែប្រួលអាកាសធាតុ បើទោះជាវាមានវឌ្ឍនភាពប្រកបដោយអត្ថន័យ ដើម្បីការពារទន្លេដ៏ធំបំផុតរបស់អាស៊ីអាគ្នេយ៍ឱ្យកាន់តែប្រសើរឡើងក៏ដោយ។

កាលពីឆ្នាំមុន បណ្ឌិត អានុល័ក គិធិឃួន (Anoulak Kittikhoun) នាយកប្រតិបត្តិលេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ បានព្រមានពីគ្រោះហានិភ័យដែលរំហូរទឹកទាបរយៈពេលបួនឆ្នាំជាប់ៗគ្នា បានបង្កើតឲ្យមាន «បញ្ហាប្រឈមដែលមិនធ្លាប់កើតមានពីមុនមក» សម្រាប់ទន្លេ និងក្រុមគ្រួសារអ្នកនេសាទ និងកសិករដែលងាយរងគ្រោះ ដែលពឹងអាស្រ័យលើទន្លេនេះ។ ក៏ប៉ុន្តែបរិមាណភ្លៀងធ្លាក់ខ្លាំងជាងមុន និងការបញ្ចេញទឹកស្តុកទុកពីផ្នែកលើនៃទន្លេ បានធ្វើឱ្យបញ្ហាប្រឈមមានភាពធូរស្រាល នៅក្នុងរយៈពេលខ្លី តែបញ្ហាប្រឈមជាច្រើនទៀតនៅតែកើតមាន។

«តើខ្ញុំមានដំណឹងល្អដែរឬទេ នៅឆ្នាំនេះ? ចម្លើយគឺមាន និង គ្មាន» បណ្ឌិត គិធិឃួន បានប្រាប់ដល់មន្ត្រីជំនាញ អ្នកការទូត និងនិស្សិតមកពីបណ្តាលសាកលវិទ្យាល័យប្រចាំតំបន់ទន្លេមេគង្គរាប់រយនាក់ ដែលបានចូលរួមក្នុងកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គ និងសន្និសីទអន្តរជាតិលើកទី៤។ «នៅឆ្នាំ២០២២ គ្រោះរាំងស្ងួតបានថយចុះ ហើយយើងមានបរិមាណភ្លៀងធ្លាក់ច្រើនជាងមុន ក៏ប៉ុន្តែស្ថានភាពបរិស្ថាន នៅតែជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួន»។

បណ្ឌិត គិធិឃួន បានបន្តប្តេជ្ញាចិត្តថាជានិច្ចកាលនឹង «រាយការណ៍ពីស្ថានភាពជាក់ស្តែង ពោលគឺពីអ្វីដែលកំពុងកើតឡើងលើទន្លេមេគង្គ និងអ្វីដែលកំពុងអនុវត្តចំពោះស្ថានភាពទាំងនោះ»។ ក៏ប៉ុន្តែ ស្របពេលដែលគណៈកម្មការទន្លេមេគង្គអន្តររដ្ឋាភិបាលមួយនេះ កំពុងដើរតួជាវេទិកានាំមុខសម្រាប់ការទូតទឹកក្នុងនាមឱ្យប្រទេសជាសមាជិក រួមមានកម្ពុជា ឡាវ ថៃ និងវៀតណាម លោកបានជំរុញឱ្យតំណាងចូលរួមទាំងអស់ថា «យើងមិនអាចធ្វើអ្វីគ្រប់យ៉ាងបានទេ។ ក្តីសង្ឃឹមរបស់យើង គឺជំរុញទឹកចិត្តគ្រប់ភាគីទាំងអស់ឱ្យបំពេញការខិតខំប្រឹងប្រែង ចន្លោះប្រហោងរបស់យើង និង/ឬធ្វើអ្វីដែលយើងមិនអាចធ្វើបាន ទៅតាម តួនាទី និងចំណាប់អារម្មណ៍រៀងៗខ្លួន»។

ដោយចាប់ផ្តើមពី «ព័ត៌មានដ៏គួរឱ្យព្រួយបារម្ភ» បណ្ឌិត គិធិឃួន បានពណ៌នាអំពីនិន្នាការដ៏គួរឱ្យព្រួយបារម្ភទាំងប្រាំខាងលើនេះ។

ដំបូងបង្អស់គឺពីរបបរំហូរទឹក។ យោងតាមការតាមដានរបស់គណៈកម្មការទន្លេមេគង្គ ក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ គេបានសង្កេតឃើញថា រំហូរទឹកនារដូវប្រាំងមានកម្រិតខ្ពស់ជាងមុន ប៉ុន្តែវាមានកម្រិតទាបជាងនៅរដូវទឹកវស្សា។ ស្ថានភាពនេះ បានបង្ហាញច្បាស់បំផុតនៅបឹងទន្លេសាប ដែលជាបឹងដ៏ធំជាងគេបំផុត និងមានផលិតភាពខ្ពស់បំផុតនៅក្នុងតំបន់ ដែលត្រូវបានគេពណ៌នាថាជា «ចង្វាក់បេះដូងនៃទន្លេមេគង្គ»។ កាលពីខែធ្នូឆ្នាំមុន រំហូរទឹកចេញពីបឹងទន្លេសាប ទៅក្នុងទន្លេមេគង្គ មានបរិមាណត្រឹមតែពាក់កណ្ដាលនៃកម្រិតរំហូរកាលពីឆ្នាំ១៩៩៥ ប៉ុណ្ណោះ។ បណ្ឌិត គិធិឃួន បានសង្កត់ធ្ងន់ថា «ខ្ញុំសូមនិយាយម្តងទៀតថា វាមានត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ»។

សម្រាប់កំណកល្បាប់វិញ ការបង្អាក់កករនៅផ្នែកខាងលើទន្លេ និងការបូមយកខ្សាច់ បានធ្វើឱ្យបរិមាណកំណកល្បាប់នៅតាមផ្នែកខ្លះៗ ធ្លាក់ចុះយ៉ាងច្រើន គឺចាប់ពីកម្រិត៦០% និង៩០%។ ប្រការនេះអាចប៉ះពាល់ដល់ផលិតភាពតំបន់លិចទឹក និងស្ថិរភាពច្រាំងទន្លេ។ បណ្ឌិត គិធិឃួន មានប្រសាសន៍ថា៖ «ទន្លេមេគង្គមិនអាចបន្តបាត់បង់ដីល្បាប់ទៀតទេ បើមិនដូច្នេះទេ វានឹងលែងក្លាយជាទន្លេមេគង្គទៀតហើយ។»

ការកើនឡើងសារធាតុជាតិប្រៃ គឺជាក្តីកង្វល់មួយទៀត ដោយផ្នែកខ្លះនៃតំបន់ដីសណ្តទន្លេមេគង្គមានកម្ពស់ត្រឹមតែពីរម៉ែត្រ ពីលើកំពស់ទឹកសមុទ្រ។ កំហាប់ជាតិប្រៃលើសពី ១ក្រាម/លីត្រ ផ្តល់ផលវិបាកជាច្រើនលើប្រព័ន្ធជាវសាស្ត្រ។ បច្ចុប្បន្ននេះ គណៈកម្មការទន្លេមេគង្គ វាស់ឃើញមានកំហាប់ជាតិប្រៃ ៤ដងនោះគឺ ៤ក្រាម/លីត្រ លើផ្ទៃដីទំហំ១៣៨ គីឡូម៉ែត្រការ៉េបន្ថែមទៀត ជារៀងរាល់ឆ្នាំ។ បណ្ឌិត គិធិឃួន លើកឡើងថា ស្ថានភាពបែបនេះ អាចធ្វើឲ្យខូចដំណាំស្រូវ «ដែលអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខស្បៀង និងការនាំចេញ»។

ទិដ្ឋភាពទី៤ គឺការបំពុលដោយប្លាស្ទិក។ ទន្លេមេគង្គ ត្រូវបានគេប៉ាន់ស្មានរួចមកហើយថាបរិមាណសំណល់ប្លាស្ទិកដ៏ច្រើនបំផុតលំដាប់ទី១០ គឺចន្លោះពី១៧.៤ ទៅ១០១ តោនក្នុងមួយថ្ងៃបានហូរចាក់ចូលទៅក្នុងមហាសមុទ្រនានា នៅក្នុងពិភពលោក ។ បណ្ឌិត គិធិឃួន បានមានប្រសាសន៍ថា «កាកសំណល់ទាំងនេះ មានទំហំប៉ុនត្រីបាឡែនដ៏ធំ ដែលត្រូវបានគេបោះចោលទៅក្នុងមហាសមុទ្រជារៀងរាល់ថ្ងៃ។» មីក្រូប្លាស្ទិកទាំងនេះ អាក្រក់ដូចឧក្រិដ្ឋជនចឹង ព្រោះវាល្អិតពេក ពិបាកនឹងមើលមិនឃើញ។ ត្រី អាចស៊ីប្លាស្ទិកទាំងនេះ ដែលអាចបំពុលដល់សង្វាក់ម្ហូបអាហាររបស់មនុស្ស។

ទិដ្ឋភាពទី៥ ការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតកាន់តែធ្ងន់ធ្ងរឡើង។ ខណៈពេលដែលចំនួន «ថ្ងៃដែលមានភ្លៀងធ្លាក់ខ្លាំង» បានថយចុះយ៉ាងខ្លាំងនៅក្នុងអាងទន្លេមេគង្គក្រោម តែនៅពេលដែលមានធ្លាក់ភ្លៀង វាធ្លាក់និងបក់បោកយ៉ាងខ្លាំង៖ នៅរដូវវស្សាឆ្នាំ២០១៨ និង២០០០ «

ចំនួនប្រជាជនដែលរងគ្រោះដោយទឹកជំនន់បានកើនឡើងរហូតដល់ ១២លាននាក់។» ទន្ទឹមនឹងនេះ ភាពញឹកញាប់នៃគ្រោះរាំងស្ងួតបានកើនឡើងក្នុងរយៈពេល ១០ឆ្នាំ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២០ បើធៀបនឹងទសវត្សរ៍មុន។

ចំពោះចំណុចវិជ្ជមាន រួមមានគុណភាពទឹកតាមដងទន្លេមេគង្គ នៅតែមានសភាព «ល្អ» ឬ «ល្អឥតខ្ចោះ» នៅតាមតំបន់ភាគច្រើន។ កំណើនសេដ្ឋកិច្ច-សង្គម និងកម្រិតជីវភាពបានកើនឡើងនៅទូទាំងតំបន់ ជាពិសេសមុនពេលមានការរាតត្បាតនៃជំងឺកូវីដ។ បណ្ឌិត គិធិឃួន ក៏បានរៀបរាប់ពីសកម្មភាពរបស់គណៈកម្មការទន្លេមេគង្គមួយចំនួន ក្នុងអំឡុងឆ្នាំ២០២២ ដែលនឹងត្រូវបោះពុម្ពផ្សាយលម្អិត នាពេលឆាប់ៗ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំ។ តួយ៉ាង គោលការណ៍ណែនាំថ្មីសម្រាប់ការរៀបចំប្លង់សាងសង់ទំនប់វារីអគ្គិសនី និងផលប៉ះពាល់បរិស្ថានឆ្លងដែន ដើម្បីសម្រួលដល់បំលាស់ទីរបស់ត្រី, ច្បាប់នាវាចរណ៍ថ្មី ដើម្បីលើកកម្ពស់សុវត្ថិភាពទន្លេឲ្យកាន់តែប្រសើជាងមុន, ឧបករណ៍ប្រកបដោយនវានុវត្តន៍ ដើម្បីព្យាករណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួតឱ្យបានប្រសើរជាងមុន, ស្ថានីយ៍តាមដានថ្មីនៅលើចុងភាគខាងជើងនៃអាងទន្លេ ដើម្បីកំណត់រកការប្រែប្រួលកម្រិតទឹកឱ្យបានឆាប់រហ័ស និងការចាប់ផ្តើមការសិក្សាស្រាវជ្រាវរួមគ្នា រួមជាមួយនឹងកិច្ចសហប្រតិបត្តិការឡានឆាង-មេគង្គ ដើម្បីបង្កើតការយល់ដឹងរួមគ្នាអំពីការផ្លាស់ប្តូររបបរំហូរទឹក នៅផ្នែកខាងលើ និងផ្នែកខាងក្រោមទន្លេ ដែលជាលក្ខខណ្ឌតម្រូវដំបូងសម្រាប់កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាងមុន។ បណ្ឌិត គិធិឃួន បានមានប្រសាសន៍ថា កិច្ចការទាំងនេះ គប្បីផ្អែកលើវិទ្យាសាស្ត្រ មិនមែនលើអារម្មណ៍ទេ។

នាយកប្រតិបត្តិនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ បានបញ្ចប់សុន្ទរកថា ជាមួយនឹងការអំពាវនាវឱ្យមានវិធានការបន្ទាន់។ ខណៈដែលកាលពីឆ្នាំមុនលោកបានអំពាវនាវថា «យើងគប្បីខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមទាំងនេះ (ន័យធៀប ពន្លត់ភ្លើងដែលកំពុងឆេះ)» ថ្ងៃនេះ លោកបានលើកឡើងថា «យើងមិនគួរចាក់ប្រេងទៅលើភ្លើងទេ។ យើងអំពាវនាវឲ្យប្រទេសតាមដងទន្លេមេគង្គ ដៃគូនិងភាគីពាក់ព័ន្ធទាំងអស់ធ្វើសកម្មភាព។ ក៏ប៉ុន្តែ វិធីដែលយើងជ្រើសរើសអនុវត្ត និងវិធីដែលមិត្តរបស់យើងទាំងក្នុងនិងក្រៅតំបន់អនុវត្ត នឹងកំណត់ជោគវាសនារបស់ទន្លេមេគង្គ ក៏ដូចជាជោគវាសនារបស់យើងទាំងអស់គ្នាដែរ»។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជាជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីអភិវឌ្ឍន៍តំបន់នេះប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

លោក មាស សុភក្រ្ត មន្ត្រីជំនាញផ្នែកភាគីពាក់ព័ន្ធ
មន្ត្រីសារព័ត៌មានបណ្តោះអាសន្ន
លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរស័ព្ទដៃ៖ +៨៥៦-២០-៧៧៧៧៩១៦៨

###